ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់តាអួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨ - ២០១០)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | :អន្លង់តាអួរ |
| ភូមិ | :អន្លង់តាអួរ |
| ឃុំ /សង្កាត់ | :កោះជីវាំង |
| ស្រុក/ខណ្ឌ | :ឯកភ្នំ |
| ខេត្ត /ក្រុង | :បាត់ដំបង |

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ អន្លង់តាអួរត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០១ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

សហគមន៍នេសាទ អន្លង់តាអួរ មានទីតាំងស្ថិតនៅក្នុងភូមិ អន្លង់តាអួរ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលមានសមាជិកសរុបចំនួន៤៣៦ នាក់ ស្រីចំនួន ២០១ នាក់ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន ០១នាក់។ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន ៣៧៥គ្រួសារ មនុស្សរាយ១០៤៧ ស្រី៥៧៩នាក់ ប្រុស៩៤៩នាក់។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ ការផ្សព្វផ្សាយបរិស្ថាន ការចុះល្បាត ការប្រជុំបណ្តាញ ការប្រជុំប្រចាំខែ ការផ្សព្វផ្សាយពីការធ្វើនេសាទខុសច្បាប់ និងការដុតបំផ្លាញព្រៃឈើ និង សត្វព្រៃ...។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

-ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមានចំនួន១០៤៧នាក់ ប្រុសចំនួន៤៦៨ នាក់ ស្រីចំនួន ៥៧៩នាក់ ក្នុងនោះ

មានជនជាតិខ្មែរចំនួន ១០៤៧នាក់ ខ្មែរឥស្លាមចំនួន 0នាក់ អាណិកជនវៀតណាមចំនួន0 នាក់ ។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៥២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០៨នាក់ ស្រី ០៤ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៣0នាក់ ស្រី ២0 នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន០៧នាក់ ស្រី ០៥ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទ មាន០៥នាក់ ស្រី ០៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១00%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន២៩៦នាក់ ស្រី៣៥៨ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន២២៤នាក់ ស្រី ២៤៤នាក់ កំរិតមធ្យមសិក្សា ចំនួន ២0នាក់ ស្រី ០៩នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ៣នាក់ ស្រី 0នាក់

**ខ -មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

-ធ្វើនេសាទត្រី ចំនួន ២៧៣ គ្រួសារ

- លក់ដូរ ចំនួន ១៩ គ្រួសារ

- លក់បន្លែ ចំនួន ២ គ្រួសារ

- កែច្នៃផលនេសាទ ចំនួន ១ គ្រួសារ

- ចិញ្ចឹមត្រី ចំនួន ៣២ គ្រួសារ ចំនួន ៣២ បែរ

- ចិញ្ចឹមក្រពើ ចំនួន ៥១ គ្រួសារ ចំនួន ៥១ បែរ

- ចិញ្ចឹមមាន់ទា-ជ្រូក ចំនួន ១៦ គ្រួសារ ១៦ ក្បាល

- ជាងជួសជុល ចំនួន ៣ គ្រួសារ

- អ្នកទិញត្រី ចំនួន ៣២ គ្រួសារ

- ជាងកាត់សក់ ចំនួន ២ គ្រួសារ

- ជាងភ្លើង ចំនួន ២ គ្រួសារ

- សិប្បកម្មកែច្នៃកំប៉ោក ចំនួន ៨ គ្រួសារ

- កម្មករជួសមង ចំនួន ១៤ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ អន្លង់តាអួរ ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ០៣ ខេត្តបាត់ដំបង ។

កន្លែងនេសាទសហគមន៍ អន្លង់តាអួរ មានទំហំ ១៨៧២ ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់:

-ខាងជើងទល់នឹង ជាប់សហគមន៍នេសាទខេត្តសៀមរាប

-ខាងត្បូងទល់នឹង ស្ទឹងសង្កែ

-ខាងកើតទល់នឹង ជាប់សហគមន៍នេសាទ ព្រែកទាល់

-ខាងលិចទល់នឹង ជាប់សហគមន៍នេសាទ កំពង់ប្រហុក

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ អន្លង់តាអួរ មានបឹងចំនួន០៨ ព្រែកចំនួន០៥ អូរចំនួន០៧ ។

-ព្រែកដូនមាស ទំហំ ២៥០០x៦០ x១,៥ ម នេសាទពីខែ១ ដល់ខែ៦

-ព្រែកអន្លង់សំណរ ទំហំ ១២០០x៥០ x១,៦ម នេសាទពីខែ១ ដល់ខែ៦

-ព្រែកតាមិល ទំហំ ៩០០x៣០ x១,៦ម នេសាទពីខែ១ ដល់ខែ៦

-ព្រែកតាមោក ទំហំ ១៥០០x២០ x១,៦ម នេសាទពីខែ១ ដល់ខែ៦

-ព្រែកប្រលាយតាចេក ទំហំ ១២០០x១៥ x១,៦ ម នេសាទពីខែ១ ដល់ខែ៦

-អូរស្នោញចងក ទំហំ ១៥០x២x១ ម នេសាទពីខែ១ ដល់ខែ៤

-អូរបឹងវែង ទំហំ ៦០x០,៨x០,៧០ ម នេសាទពីខែ១ ដល់ខែ៤

-អូរតាមិល ទំហំ ៤០០x១,៥ x ០,៧ ម នេសាទពីខែ១ ដល់ខែ៤

-អូរតាមោក ទំហំ ៤០x១ x០,៦ ម នេសាទពីខែ១ ដល់ខែ៤

-អូររហាលតាម៉ុក ទំហំ ១៣០x២ x១,២ម នេសាទពីខែ១ ដល់ខែ៤

- អូរប្រឡាយតាចេកទាល់ ទំហំ ២០០x២,៥ x១,៤ ម នេសាទពីខែ១ ដល់ខែ៤

- អូរដៃអារ ទំហំ ៤០០x២ x០,៨ ម នេសាទពីខែ១ ដល់ខែ៤

- បឹងវែងដូនមាស ទំហំ ១៥០x៦០ x១,៥ ម នេសាទពីខែ១ ដល់ខែ៤

- បឹងក្រសា ទំហំ ៥០x៥០ x១,៤ ម នេសាទពីខែ១ ដល់ខែ៤

- បឹងសារាយ ទំហំ ១០០x៣០ x១ ម នេសាទពីខែ១ ដល់ខែ៤

- បឹងសំរៈ ទំហំ ១០០x៣៥ x១,៧ ម នេសាទពីខែ១ ដល់ខែ៤

- បឹងរូង ទំហំ ៣០x២០ x១,៥ ម នេសាទពីខែ១ ដល់ខែ៤

- បឹងចាក់ជ្រក់ ទំហំ ១៥x ១៥x១,៣ ម នេសាទពីខែ១ ដល់ខែ៤

-បឹងឆ្កោក ទំហំ ១៥០x៥០ x១,៤ ម នេសាទពីខែ១ ដល់ខែ៤

- បឹងក្បាលខ្មោច ទំហំ ៧០x៥០ x១,៤ ម នេសាទពីខែ១ ដល់ខែ៤

-ព្រែកម្តោត និងព្រៃរនាមលិចទឹកមានទំហំប្រហែល ១៦១០.២៦ ហិកតា

-ស្មៅលិចទឹកមានទំហំប្រហែល ១៥០.៩៧ ហិកតា

-ផ្ទៃទឹក(បឹង ទន្លេ ស្ទឹង ព្រែក អូរ) មានទំហំប្រហែល ១១០.៥៥ហិកតា

-ដីភូមិ ចំការក្នុងភូមិមានទំហំប្រហែល ០.៤២ ហិកតា

-វាលភក់មានទំហំប្រហែល ៦.៣៨ ហិកតា

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

-បឹងឆ្កោក (ក្រោយវត្តអន្លង់តាអូរ) មានប្រវែងបណ្តោយប្រហែល ១៥០ម ទទឹង ៥០ម ជំរៅ១,៥។

**ឃ. ធនធានជលផល**

តាមការសិក្សាប្រមូលព័ត៌មាននូវធនធានជលផល ក្នុងកន្លែងនេសាទសហគមន៍កោះជីវាំងមានត្រីចំនួន ៦៥ ប្រភេទ វារីសត្វចំនួន ៣១ ប្រភេទ ព្រៃលិចទឹក ចំនួន ៣១ ប្រភេទ និងវារីរុក្ខជាតិ ចំនួន ២២ ប្រភេទ។ មានដូចខាងក្រោម៖

-ប្រភេទត្រី ( ត្រីឆ្ពោរ ត្រីរស់ សណ្តាយ ត្រីដឺរ ត្រីតាអោន ត្រីរៀល ត្រីប្រា ត្រីអណ្តែង ត្រីព្រួល ត្រីក្រាយ ត្រីកំភ្លាញ ត្រីកំភ្លៀវ ត្រីកញ្ចុះ ត្រីខ្នាន់ ត្រីក្រុះ ត្រីលីញ ត្រីក្អែក ត្រីកញ្ចុះប្រាក់ ត្រីកំភ្លៀវទឹកបាយ ត្រីកញ្រ្ជូក ត្រីកន្ធរ ត្រីអណ្តាតឆ្កែត្រីខ្ទីង ត្រីពោរ ត្រីត្រសក់ ត្រីក្រាញ់ ត្រីឆ្លូញ ត្រីក្រឹមជល់ ត្រីក្រឹមក្តារ ត្រីរំចេក ត្រីកន្ទ្រង់ប្រេង ត្រីឆ្លាំង ត្រីផ្ទោង ត្រីស្លាត ត្រីកាហែ ត្រីកន្ធ្រប់ ត្រីចង្វាពោត ត្រីប្រម៉ា ត្រីឆ្មូត ត្រីកន្ទ្រប់ខ្លា ត្រីគល់រាំង ត្រីក្រាយ ត្រីឆ្ពិន ត្រីគ្រុំ ត្រីចង្វាមូល ត្រីកំភ្លាញភ្លុក ត្រីសង្កត់ប្រាក់ ត្រីអំពិលទុំ ត្រីក្បាន្ត ត្រីអណ្តែង ត្រីកញ្ជន ត្រីក្រុះខ្នងវែង ត្រីក្រុះមេម៉ាយ ត្រីកំព្រាម ត្រីស្លឹកឬស្សី ត្រីចន្ទាភ្លុក ត្រីឆ្កោក ត្រីចាកែង ត្រីក្រពាត់ ត្រីឆ្លាំងតានេល ត្រីកេះ ត្រីឆ្លាំងហាយ ត្រីកន្ទុយមាន់ ត្រីកាជះខ្លា ត្រីកំបុតច្រមុះ ត្រីកៀតត្រង់)

-ប្រភេទវារីសត្វ ( ពក់វែក ពស់ថ្លាន់ ពស់ត្រីរស់ ក្រពើ អន្ទង់ អណ្តើក កន្ធាយ ទន្សង តេ ស្វាស ស្វាខ្មៅ កង្កែប សំពោច ពស់ព្រលិត ពស់តាចាន់ ពស់ដូង ពស់សំលាប់កង្កែប ពស់ឈើ ពស់វែកក្របី ពស់វែកតំបូក ពស់វែកស្រវែង ពស់ស្រកាចាស់ ខ្ចង ខ្ចៅ គ្រុំ ក្តាម លាស កន្ធេះឡង់ កំពឹស ពស់ផ្ទុក ពស់ខៀវ )

-ប្រភេទព្រៃលិចទឹក ( ដើមថុល ដើមរាំង ដើមត្នូរ ដើមកន្ស្រែង ដើមតាសេក ដើមភ្លុំភ្លៀង ដើមក្លួង ដើមត្រស់ ដើមថ្វាន់ ដើមសណ្តាន់ ដើមមដេញ ដើមអាទាំង ដើមតាឡក ដើមតាដក់ ដើមបបួយ ដើមកណ្តប់ចង្អេរ ដើមខ្ទុម្ព ដើមទៀនព្រៃ ផ្ទោល ច្រកែង គ្រោះ បន្លាស្អិត បន្លាភេ អាវក្រពើ សន្ទែ ក្តរស្វា អញ្ចូង ប្រហាច បន្លាយួន ផ្តៅ)

-ប្រភេទវារីរុក្ខជាតិ ( វល្លិ៍ប្រេង វល្លិ៍ដោះគន់ ដើមផ្តៅ វល្លិ៍តាអើក សារាយទឹក កក់ វល្លិ៍ត្រី វល្លិ៍តាជិត ដើមត្រែង ដើមស្រវែង ដើមកំប្លោក ដើមព្រលិត ដើមស្នោ ត្រកួន ចក សួង កន្រ្តាំងហែ ស្មៅចំផ្លង ស្មៅល្អាក់ទឹក ស្មៅបារាំង បបុះ ស្មៅកណ្តូប )

( ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ ទី១ ភ្ជាប់មកជាមួយ)

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៤៣៦ នាក់ ស្រី ២០១ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៦១១ នាក់ ស្រី ៣៧៨ នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៦៤០ នាក់ ស្រី១៦៥នាក់

### ខ. ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូក កាណូតរបស់សមាជិកសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/ទំហំ មធ្យម | ចំនួនអ្នកនេសាទ ជាសមាជិក | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ ( ខែ...ដល់ ខែ...) |
|---|---|---|---|---|---|
| បរត្រី | ឡូក | ១ | ១០០ | ១០០ | មករាដល់មីនា និងខែធ្នូ |

| | | | | | |
|---|---|---|---|---|---|
| មងរាយ | ដៃ-៤០ម | ៥ | ៣០ | ១៥០ | មករា ដល់មីនានិងខែធ្នូ |
| សន្ទូច | វនង-២០០ផ្លែ | ២ | ១០០ | ២០០ | មករា ដល់មីនា និងខែធ្នូ |
| ឡើ | គ្រឿង | ២០ | ៣០ | ៦០០ | មករា ដល់មីនា និងខែធ្នូ |
| ណាវ៉ា | ខ្សែ/១២០០ ម | ១ | ១ | ១ | តុលា ដល់ធ្នូ |
| មងប្រយ៉ុង | ខ្សែ/៤០ម | ១ | ១ | ១ | មីនា ដល់មេសា |
| លាន់ | គ្រឿង | ៥០ | | | កក្កដា ដល់សីហា |
| លួង | គ្រឿង | ២០ | | | មេសា ដល់មិថុនា |
| ឆក់ | គ្រឿង | ១ | | | កុម្ភៈ ដល់មេសា |
| សំណាញ់ | វង់ | ១ | | | មីនា ដល់មេសា |
| មងហ៊ុំ | ខ្សែ | ១ | | | កុម្ភៈ ដលមេសា |

| **ប្រភេទទូក -កាណូត** | **ចំនួន** | **សមត្ថភាព/ចំណុះ /ទំហំ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកអុំទូកចែវ | ៤៥១ | ៥x១,១x0,៤<br>៧x១,៣x0,៦ | |
| កាណូតម៉ាស៊ីនសាំង | ៨0 | ៥ x ១,១ x 0,៤ | ៥,៥-៩សេះ |
| ការណូតម៉ាស៊ីនកៅហ្វុង | ២៥ | ៧ x ១,៣ x 0,៦ | ១២-២២សេះ |
| កាណូតម៉ាស៊ីន | ៥ | ៨-១0 x ១,៥ x 0,៨ | ២៣-២៥សេះ |
| កាណូតម៉ាស៊ីន | ៥0 | ១0-១២ x ១,៨ x ១,១ | ២៦-៣៥សេះ |
| កាណូតម៉ាស៊ីន | ៤ | ១0-១២ x ១,៨ x ១,១ | -៣៦សេះឡើង |

-ឧបករណ៏នេសាទដែលប្រើ ក្នុងកន្លែងនេសាទសហគមន៏ ដោយអ្នកមិនមែនជាសមាជិក ក្នុងភូមិអន្លង់តាអួរ

| **ប្រភេទឧបករណ៏** | **ឯកតា** | **ចំនួន/ទំហំមធ្យម** | **ចំនួនអ្នកនេសាទមិនមែនជាសមាជិក** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៏ ( ខែ...ដល់ ខែ...)** |
|---|---|---|---|---|---|
| បរត្រី | ឡូក | ១ | ៦0 | ៦0 | មករា-មីនា និងធ្នូ |
| មងរាយ | ដៃ-៤០ម | ៥ | ៤៥ | ២២៥ | មករា-មីនា និងធ្នូ |
| សន្ទូច | វនង-២០០ផ្លែ | ២ | ៦0 | ១២0 | មករា-មីនា និងធ្នូ |
| ឡើ | គ្រឿង | ២0 | ៥៥ | ១.១00 | មករា-មីនា និងធ្នូ |

| | | | | | |
|---|---|---|---|---|---|
| ណាំវ | ខ្សែ/១២០០ម | ១ | ១ | ១ | តុលា-ធ្នូ |
| មងប្រយ៉ុង | ខ្សែ/៤០ម | ១ | ១ | ១ | មីនា-មេសា |
| លាន់ | គ្រឿង | ៥០ | ២០ | ១០០ | កក្កដា-សីហា |
| លូង | គ្រឿង | ២០ | ៣ | ៦០ | មេសា-មិថុនា |
| ឆក់ | គ្រឿង | ១ | ៥ | ៥ | កុម្ភៈ-មេសា |
| សំណាញ់ | វង់ | ១ | ២៥០ | | មីនា-មេសា |
| មងហ៊ុ | ខ្សែ | ១ | ៥ | ៥ | កុម្ភៈ-មេសា |

| ប្រភេទទូក-កាណូត | ចំនួន | សមត្ថភាព/ចំណុះ/ទំហំ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំទូកចែវ | ១៤៩ | ៥x១,១x0,៤<br>៧x១,៣x0,៦ | |
| កាណូតម៉ាស៊ីនសាំង | ៤៥ | ៥ x ១,១ x 0,៤ | ៥,៥-៩សេះ |
| ការណូតម៉ាស៊ីនកៅហ្វុង | ៣០ | ៧ x ១,៣ x 0,៦ | ១២-២២សេះ |
| កាណូតម៉ាស៊ីន | ១០ | ៨-១០ x ១,៥ x 0,៨ | ២៣-២៥សេះ |
| កាណូតម៉ាស៊ីន | ១០០ | ១០-១២ x ១,៨ x ១,១ | ២៦-៣៥សេះ |

-ឧបករណ៍នេសាទ និងទូក-កាណូតរបស់អ្នកនៅក្នុងសហគមន៍ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន/ទំហំ (មធ្យម) | ចំនួនអ្នកនេសាទ | ចំនួន/ទំហំសរុប | រដូវប្រើប្រាស់ឧបករណ៍ ( ខែ...ដល់ ខែ...) |
|---|---|---|---|---|---|
| បរត្រី | ឡូក | ១ | ៤០ | ៤០ | មករា-មីនា |
| មងរាយ | ដៃ-៤០ម | ៥ | ២០ | ១០០ | មករា ដល់មីនា និងខែធ្នូ |
| សន្ទូច | រនង-២០០ផ្លែ | ២ | ២០ | ៤០ | មករា ដល់មីនា និងខែធ្នូ |
| ឡើ | គ្រឿង | ២០ | ២០ | ៤០ | មករា ដល់មីនា និងខែធ្នូ |
| ណាំវ | ខ្សែ/១២០០ម | ១ | ១ | ១ | សីហា-ធ្នូ |
| មងប្រយ៉ុង | ខ្សែ/៤០ម | ១ | ៤ | ៤ | មីនា-មេសា |
| លាន់ | គ្រឿង | ៥០ | ១៥ | ៧៥០ | កក្កដា-សីហា |
| លូង | គ្រឿង | ២០ | ៥០ | ១០០ | កុម្ភៈ-មេសា |
| ឆក់ | គ្រឿង | ១ | ៧០ | ៧០ | កុម្ភៈ-មេសា |
| សំណាញ់ | វង់ | ១ | ២៥០ | ២៥០ | មីនា-មេសា |
| លបផ្សំព្រួល | គ្រឿង | ៥០ | ២០ | ១០០ | មករា-កុម្ភៈ |

| ប្រភេទទូក-កាណូត | ចំនួន | សមត្ថភាព/ចំណុះ/ទំហំ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំទូកចែវ | ៨០ | ៥x១,១x0,៤<br>៧ x១,៣ x0,៦ | |
| កាណូតម៉ាស៊ីនសាំង | ៣១ | ៥ x ១,១ x 0,៤ | ៥,៥-៩សេះ |
| ការណូតម៉ាស៊ីនកៅហ្វុង | ៦ | ៧ x ១,៣ x 0,៦ | ១២-២២សេះ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ១៥0 | ១0៤ | ២៥៤ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ក. ទស្សនះវិស័យ

សហគមន៍នេសាទ អន្លង់តាអួរ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធមិ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ0៣ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៏ធនធានជលផល ជូនប្រជាពលរដ្ឋប្រកបដោយសមធម៏
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៏នេសាទ តាមរយៈការអភិវឌ្ឍន៏ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋ បានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទ នៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើង ដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | សកម្មភាព | ពេលវេលា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន/ថ្ងៃ | | | |
| បឹងក្បាលខ្មោច | មករា-មេសា | តុម | | ១០បំពង់ | -ផ្សព្វផ្សាយ | ខែមករា | រាល់ឆ្នាំ |
| | | ឡើ | | ៥០ | -ផ្លាកប្រកាស | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ |
| | | មងរាយ | ១ដៃ-៤០ម | ២ដៃ | -ចុះល្បាត | ខែមករា-ខែកក្កដា | រាល់ឆ្នាំ |
| | | លាន់ | | ៣០បំពង់ | | | |
| បឹងចាក់ជ្រក់ | មករា-មេសា | តុម | | ២០បំពង់ | -ផ្សព្វផ្សាយ | ខែមករា | រាល់ឆ្នាំ |
| | | មងរាយ | | ២ដៃ | -ផ្លាកប្រកាស | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ |
| | | ឡើ | | ៥០ | -ចុះល្បាត | ខែមករា-ខែកក្កដា | រាល់ឆ្នាំ |
| | | លាន់ | | ៣០បំពង់ | | | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ម) | ទំហំដែលត្រូវកែលំអ (ម) | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងក្បាលខ្មោច | ៧០x៥០x១,៤ម | ៣០x២០x១ម | -ស្តារល្បាប់បឹង | ៤-២០០៩ | ៦-២០០៩ | |
| បឹងចាក់ជ្រក់ | ១៥x១៥x១,៤ម | ១៥x១៥x១ម | -ស្តារល្បាប់បឹង | ៤-២០១០ | ៦-២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ | សកម្មភាព | ថ្ងៃខែឆ្នាំ | ថ្ងៃខែឆ្នាំ | ផ្សេងៗ |
|---|---|---|---|---|---|---|

| | | នៃការអភិរក្ស | | ចាប់ផ្ដើម | បញ្ចប់ | |
|---|---|---|---|---|---|---|
| បឹងឆ្កោក | ១៥០x៥០ x ១,៥ម | -ត្រីមេពូជ -ព្រៃលិចទឹក | -អប់រំផ្សព្វផ្សាយ | ១-២០០៨ | ១-២០០៨ | |
| | | | -ប្រជុំរៀបចំបទបញ្ញត្តិ | ២-២០០៨ | ២-២០០៨ | |
| | | | -ប្រជុំពិភាក្សា និងកំណត់ព្រំប្រទល់ | ៣-២០០៨ | ៣-២០០៨ | |
| | | | -ផ្លាកប្រកាស | ១-២០០៩ | ៣-២០០៩ | |
| | | | -រៀបចំស្តារ ស្រះអភិរក្ស ៧០ម x ២០ម | ៤-២០០៨ | ៦-២០០៨ | |
| | | | -រៀបចំជម្រកត្រី | ៤-២០០៩ | ១០-២០០៩ | |
| | | | -ល្បាត | ១-២០០៨ | ១២-២០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| -កន្លែងអភិរក្សត្រីមេពូជ បឹងឆ្កោក | ២ហិកតា | រាំង, ផ្ទោល, ច្រកែង | -ការជ្រើសរើសអ្នកចូលរួម និងជ្រើសរើសគ្រាប់ | កញ្ញា-០៩ | តុលា-០៩ | |
| | | | -ការរៀបចំថ្នាលបណ្ដុះកូនឈើ | មករា-១០ | មករា-១០ | |
| | | | -ដំណើរការបណ្ដុះកូនឈើ ៥ ០០០ ដើម | មករា-១០ | មិថុនា-១០ | |
| | | | -ការតាមដាន និង វាយតម្លៃ | កក្កដា-១០ | កក្កដា-១០ | |
| | | | -យុទ្ធនាការដាំកូនឈើ ៥ ០០០ ដើម | មិថុនា-១០ | មិថុនា-១០ | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីតូច | បរិមាណកូនត្រីតូច | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ការចិញ្ចឹមត្រី | ២០ ត្រើង | អណ្តែង | ៥០០០ក្បាល | មីនា ២០០៨ | កុម្ភៈ ២០០៩ |
| | ១០ ត្រើង | - | - | មីនា ២០០៩ | កុម្ភៈ ២០១០ |
| | ១០ ត្រើង | - | ៤០០០ក្បាល | កុម្ភៈ ២០១០ | ធ្នូ ២០១០ |
| ការចិញ្ចឹមត្រី | ២០ ត្រើង | ប្រា | ៥០០០ក្បាល | មីនា ២០០៨ | កុម្ភៈ ២០០៩ |
| | ១០ ត្រើង | - | - | មីនា ២០០៩ | កុម្ភៈ ២០១០ |
| | ១០ ត្រើង | - | ៤០០០ក្បាល | កុម្ភៈ ២០១០ | ធ្នូ ២០១០ |
| ការចិញ្ចឹមអន្ទង់ | ១០ ត្រើង | អន្ទង់ | ១០០គ.ក | កក្កដា ២០០៨ | មេសា ២០០៩ |
| | ១៥ ត្រើង | - | - | កក្កដា ២០០៩ | មេសា ២០១០ |
| | ២០ ត្រើង | - | - | កក្កដា ២០១០ | ធ្នូ ២០១០ |

## គ-៦-ផែនការពង្រីកមុខរបរចិញ្ចឹមជីវិត

ផែនការពង្រីកមុខរបរចិញ្ចឹមជីវិត នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ប្រភេទមុខរបរ | ចំនួនគ្រួសារ | ទំហំផលិតកម្ម ក្នុងមួយគ្រួសារ | ទំហំផលិតកម្ម សរុប | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| បណ្តុះផ្សិត | ១០ | ៥រង(១រង-៣ម) | ៥០ | មីនា ២០០៨ | ឧសភា ២០០៨ |
| | ៥ | - | ២៥ | មីនា ២០០៩ | ឧសភា ២០០៩ |
| ចិញ្ចឹមជ្រូក | ៥ | ២ក្បាល | ១០ | មករា ២០០៨ | តុលា ២០០៨ |
| | ៥ | - | ១០ | មករា ២០០៩ | តុលា ២០០៩ |
| | ៥ | - | ១០ | មករា ២០១០ | តុលា ២០១០ |
| ចិញ្ចឹមមាន់-ទាកាប៉ា | ៥០ | ៥ក្បាល | ២៥០ | មីនា ២០០៨ | តុលា ២០០៨ |
| | ២០ | - | ១០០ | មីនា ២០០៩ | តុលា ២០០៩ |
| | ១០ | - | ៥០ | មីនា ២០១០ | តុលា ២០១០ |

## គ-៧ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍន៍សហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែ | ថ្ងៃខែ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|

| | | ចាប់ផ្តើម | បញ្ចប់ | | |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ចូលថ្មី | ផ្សព្វផ្សាយជ្រើសរើសសមាជិកថ្មីចំនួន៥០នាក់ក្នុង ១ឆ្នាំ | ២០០៨ | ២០០៨ | ៥០០០០ | ១០០០៛/នាក់ |
| | | ២០០៩ | ២០០៩ | ៥០០០០ | |
| | | ២០១០ | ២០១០ | ៥០០០០ | |
| ភាគទានប្រចាំឆ្នាំរបស់សមាជិក | សមាជិក ៤២២ | ២០០៨ | ២០០៨ | ៤២២ ០០០ | ១០០០៛/នាក់ |
| | សមាជិក៤៧២ | ២០០៩ | ២០០៩ | ៤៧២ ០០០ | |
| | សមាជិក៥២២ | ២០១០ | ២០១០ | ៥២២ ០០០ | |

## គ -៤ ផែនការពង្រឹងសមត្ថភាព

ផែនការពង្រឹងសមត្ថភាពត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| សកម្មភាព | ចំនួនអ្នកចូលរួម | រយៈពេល | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | -២០នាក់ | -២ថ្ងៃ(៣ដង) | -ខែកុម្ភៈ | -ខែកុម្ភៈ | រាល់ឆ្នាំ |
| -បណ្តុះបណ្តាលបច្ចេកទេស បណ្តុះផ្សិត | -១០នាក់ | -១ថ្ងៃ(២ដង) | -ខែមិនា | -ខែមិនា | ឆ្នាំ២០០៨, ០៩ |
| -បណ្តុះបណ្តាលកិច្ចការរដ្ឋបាល | -១០នាក់ | -២ថ្ងៃ(១ដង) | -ខែមករាឆ្នាំ០៨ | -ខែមករាឆ្នាំ០៨ | |
| -បណ្តុះបណ្តាលជីអ៊ីអឹម | -១០នាក់ | -១ថ្ងៃ(២ដង) | -ខែមេសា | -ខែមេសា | ឆ្នាំ២០០៨, ០៩ |
| -បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | -១៥នាក់ | -១ថ្ងៃ | -ខែកក្កដា ឆ្នាំ២០០៨ | -ខែកក្កដា ឆ្នាំ២០០៨ | |
| -បណ្តុះបណ្តាលជំនួញខ្នាតតូច | -១៥នាក់ | ១ថ្ងៃ | -ខែមេសា ឆ្នាំ២០១០ | -ខែមេសា ឆ្នាំ២០១០ | |
| -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជន្លេន | -១៥នាក់ | ១ថ្ងៃ | -ខែមករា ឆ្នាំ២០០៩ | -ខែមករា ឆ្នាំ២០០៩ | |
| -បណ្តុះបណ្តាលបច្ចេកទេស បណ្តុះ និងដាំព្រៃលិចទឹក | ២០នាក់ | ២ថ្ងៃ | -ខែកក្កដា ឆ្នាំ២០០៨ | -ខែកក្កដា ឆ្នាំ២០០៨ | |
| -បណ្តុះបណ្តាលបច្ចេកទេសធ្វើសារពើភ័ណ្ឌព្រៃ | -១៥នាក់ | ១ថ្ងៃ | -ខែកុម្ភៈ ឆ្នាំ២០១០ | -ខែកុម្ភៈ ឆ្នាំ២០១០ | |
| -ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | -២៥០នាក់ | ៦ដង | -ខែតុលា និងខែមករា | -ខែតុលា និងខែមករា | រាល់ឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | |
| -សិក្ខាសាលាថ្នាក់ភូមិ ស្តីពី លក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ២០នាក់ | ២ថ្ងៃ | ខែកក្កដាឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| -ទស្សនៈកិច្ច សិក្សាក្រៅខេត្ត | -១០នាក់ | -៣ថ្ងៃ | -ខែ៤មេសា ឆ្នាំ២០១០ | -ខែមេសា ឆ្នាំ២០១០ | |
| -ទស្សនៈកិច្ច សិក្សាក្នុងខេត្ត | -១៥នាក់ គុណ២ | -៣ថ្ងៃ គុណ២ | -ខែវិច្ឆិកា ឆ្នាំ២០០៨, ០៩ | -ខែវិច្ឆិកា ឆ្នាំ២០០៨, ០៩ | |
| -បណ្តុះបណ្តាលស្តីពីការសរសេរគម្រោងស្នើសុំ | -១៥នាក់ | ២ថ្ងៃ | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |

## គ-៩- ផែនការចងក្រងក្រុមស្ត្រី

ផែនការចងក្រងក្រុមស្ត្រីត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ប្រភេទក្រុម | ទំហំ | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| -ក្រុមសន្សំ | ១០នាក់ (មួយក្រុម) | -ផ្សព្វផ្សាយរកអ្នកចូលរួម | មករា ២០០៨ | មករា ២០០៨ | |
| | | -រៀបចំច្បាប់ លក្ខន្តិកៈ | មីនា ២០០៨ | មីនា ២០០៨ | |
| | | -រៀបចំរចនាសម្ព័ន្ធរបស់ក្រុម | មេសា ២០០៨ | មេសា២០០៨ | |

## គ.១០ ផែនការពង្រឹងការគ្រប់គ្រង

ផែនការពង្រឹងសមត្ថភាពត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| សកម្មភាព | ទំហំ | ចំនួន | ចាប់ផ្តើម | បញ្ចប់ | ផ្សេង |
|---|---|---|---|---|---|
| -ទូកអុំ | ៥មx ១.២មx០.៥ម | ០១គ្រឿង | មីនា ២០០៨ | មេសា ២០០៨ | |
| -ទូកចែវ | ៧មx ១.៥មx០.៥ម | ០២គ្រឿង | កុម្ភៈ ២០១០ | កក្កដា ២០១០ | |
| -កាណូត | ៧មx ១.៥មx០.៧ម | ០១គ្រឿង | កុម្ភៈ ២០១០ | កក្កដា ២០១០ | ម៉ាស៊ីន៣ឡុក |
| -អាវភ្លៀង | | ២០សម្រាប់ | ឧសភា ២០០៨ | ឧសភា ២០០៨ | |
| -អង្រឹង | | ២០សម្រាប់ | ឧសភា ២០០៨ | ឧសភា ២០០៨ | |
| -ប៉ាណូ | ៣មx ២ម | ០១ផ្ទាំង | មករា ២០១០ | មេសា ២០១០ | ធ្វើពីដែក មានជើងទ្រ |
| -ល្បាត | ៣ដង/ខែx ៣៦ | ១០៨ដង | មករា ២០០៨ | ធ្នូ ២០១០ | ម្តង៥-៦នាក់ |
| -ប្រជុំគណៈកម្មការតាមដានការអនុវត្តផែនការ | | ២ដង/ឆ្នាំ | មិថុនា និងធ្នូ ២០០៨,០៩,១០ | មិថុនា និងធ្នូ ២០០៨,០៩,១០ | |

| | | | | | |
|---|---|---|---|---|---|
| -ប្រជុំប្រចាំខែ | ១ដង x៣៦ខែ | ៣៦ដង | ២០០៨ | ២០១០ | រាល់ចុងខែ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

-បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រីការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់

-ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូរសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍

-ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អន្លង់តាអួរ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | ១-១-ផ្សព្វផ្សាយជាសាធារណៈ តាមឧឃោសនសព្ទពីការសាកល្បងរក្សា ទុកបឹងក្បាលខ្មោច និងបឹងចាក់ជ្រក់ដាក់ ឱ្យមានការគ្រប់គ្រងច្បាស់លាស់ | -ប្រជានេសាទយ៉ាងហោចណាស់៨៥% គាំទ្រយន្តការ<br>-បឹងចំនួន០២ នឹងមានការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព | ១២០ ០០០រៀល | សហគមន៍នេសាទ | ខែមករា | ខែមករា | រាល់ឆ្នាំ |
| | ១-២-រៀបចំផ្លាកសញ្ញា ដែលថែងអំពីយន្តការគ្រប់គ្រង | -ប្រជានេសាទ នឹងចូលរួមគោរពតាមការណែនាំ<br>-ផ្លាកធ្វើអំពីដែកចំនួន ពីរផ្ទាំងនឹងតាំងឡើង ត្រង់ច្រកចេញចូល នៃបឹងទាំងពីរ | ៣០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សប្បុរសជន . | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ | |
| | ១-៣-ការយាមល្បាត ពង្រឹងការគ្រប់គ្រងបឹងទាំងពីរ | -ក្រុមល្បាតដែលមានគ្នាយ៉ាងតិច៥នាក់ ចូលរួមល្បាត ៤ដងក្នុងមួយខែ<br>-ការគ្រប់គ្រង មានដំណើរការរលូន និងមានបន្សល់ត្រីពូជក្នុងបឹងនិមួយៗ | ២ ៤០៤ ៨០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា | ខែកក្កដា | រាល់ឆ្នាំ |
| ២- ការកែលំអដែននេសាទ | ២-១-ស្តារបឹងក្បាលខ្មោច និងបឹងចាក់ជ្រក់ ដោយប្រើកំលាំង ពលកម្ម | -ល្បាប់បាតបឹង ចំនួន២ ៨២៥ម៣ ដែលមានជម្រៅ ១ម ត្រូវស្តារមកខ្ទង់មាត់បឹង<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រី | ៨ ២៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមេសា ឆ្នាំ២០០៩ និង២០១០ | ខែមិថុនា ឆ្នាំ២០០៩ និង២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ត្រូវកែលំអ | | | | | |
| ៣- ការកំណត់ និង រៀបចំតំបន់អភិរក្ស | ៣-១-ប្រជុំពិភាក្សាជាមួយ អ្នកពាក់ព័ន្ធ ដើម្បីបង្កើត កន្លែងអភិរក្សត្រីមេពូជ និង ព្រៃលិចទឹក | -បឹងឆ្កោក បណ្តោយ ១៥០ម ទទឹង៥០ម និងព្រៃ ជុំវិញបឹង ទទួលការឯកភាពរក្សាទុកជា កន្លែងអភិរក្ស<br>-អ្នកចូលរួម យ៉ាងតិច២០នាក់ នឹងបានយល់កាន់ តែច្បាស់ពី អត្ថប្រយោជន៏នៃការបង្កើត កន្លែងអភិរក្ស | ៦០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |
| | ៣-២-ប្រជុំរៀបចំបទបញ្ញត្តិ និងគោលការណ៏គ្រប់គ្រង កន្លែងអភិរក្ស | -សហគមន៏ និងអ្នកពាក់ព័ន្ធ យ៉ាងតិច២០នាក់ ចូលរួម ពិភាក្សា និងផ្តល់យោបល់<br>-យន្តការគ្រប់គ្រង នឹងត្រូវបាន កំណត់ច្បាស់លាស់ និងមានការ ទទួលខុសត្រូវ | ៦០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |
| | ៣-៣-ការប្រជុំពិភាក្សា និង ចុះកំណត់ព្រំប្រទល់កន្លែង អភិរក្ស | -ទីតាំងសំខាន់ៗនៃព្រំប្រទល់ កន្លែងអភិរក្ស ត្រូវបានកំណត់ និងដៅច្បាស់លាស់<br>-បង្គោល និងផ្លាកសញ្ញា សំគាល់ព្រំប្រទល់ ត្រូវបានដាក់ នៅនឹងកន្លែង | ១៧៧ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៏ នេសាទ | ខែមីនា ឆ្នាំ២០០៨ | ខែមីនា ឆ្នាំ២០០៨ | |
| | ៣-៤-រៀបចំផ្ទាំងប៉ាណូ ផ្សព្វផ្សាយកន្លែងអភិរក្ស | -ផ្ទាំងប៉ាណូ ធ្វើអំពីដែក បណ្តោយ២,៥ម ទទឹង១,៨ម ចំនួន០២ផ្ទាំង នឹងត្រូវដាក់តាំង តាមច្រកសំខាន់ៗ | ២ ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមករា ឆ្នាំ២០០៩ | ខែមីនា ឆ្នាំ២០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | -ប្រជាពលរដ្ឋយល់ និងចូលរួមគ្រប់គ្រងកន្លែងអភិរក្ស | | | | | |
| | ៣-៥-ការជីកស្តារស្រះកន្លែងអភិរក្សត្រីមេពូជ | -ល្បាប់បាតស្រះ ប្រវែង៧០ម ដែលមានទទឹង២០ម និងជម្រៅ ១ម ត្រូវស្តារមកខ្វងស្រះ<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រីត្រូវកែលំអ | ១ ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, | ខែមេសា ឆ្នាំ២០០៨ | ខែមិថុនា ឆ្នាំ២០០៨ | |
| | ៣-៦-ការរៀបចំធ្វើជម្រកត្រីក្នុងកន្លែងអភិរក្ស | -គល់ឈើ ១៥គល់ បង្គោលថ្ម ១០ដើម និងលូស៊ីម៉ង់ ២០លូ ត្រូវបានដាក់ក្នុងកន្លែង អភិរក្ស<br>-ប្រព័ន្ធអេកូឡូស៊ី ជម្រកត្រីត្រូវកែលំអ ជាសំបុកពងកូន និងទីសុវត្ថិភាព | ៦៩៦ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៩ | ខែតុលា ឆ្នាំ២០០៩ | |
| | ៣-៧-ការធ្វើសារពើភ័ណ្ឌព្រៃលិចទឹក | -សមាសភាព ប្រភេទ ចំនួន ដង់ស៊ីតេ រុក្ខជាតិព្រៃលិចទឹក ត្រូវបានកត់ត្រា<br>-កំណត់បានយន្តការគ្រប់គ្រងព្រៃបានត្រឹមត្រូវ | ៧៨០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៩ | ខែឧសភា ឆ្នាំ២០០៩ | |
| | ៣-៨-ការរៀបចំធ្វើអនាម័យព្រៃលិចទឹក | -ប្រភេទរុក្ខជាតិ ចង្រៃ ត្រូវបានបំផ្លាញចោល<br>-រុក្ខជាតិព្រៃលិចទឹក មានសុខ-ភាពល្អ និងសុវត្ថិភាព | ១ ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០១០ | ខែមិថុនា ឆ្នាំ២០១០ | |
| | ៣-៩-ការរៀបចំធ្វើផ្លូវការ-ពារភ្លើងឆេះព្រៃអភិរក្ស | -របាំងការពារការរាលដាលភ្លើងឆេះព្រៃ ត្រូវបានបង្កើត | ៤ ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ | ខែកុម្ភៈ ឆ្នាំ២០១០ | ខែមិថុនា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ឡើង ដែលមានប្រវែង២ ០០០ម ទទឹង៥ម | | នេសាទ | | | |
| | ៣-១០-កសាងខ្ទមអ្នកតា | -ខ្ទមអ្នកតា បណ្តោយ៣ម ទទឹង២ម និងកំពស់៣,៥ម ត្រូវបានកសាង ជាទីសក្ការៈ<br>-ព្រៃលិចទឹក ត្រូវបានគោរព ថែរក្សា និងស្រឡាញ់ ដូចអ្នកតា | ១ ៩០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០០៩ | ខែឧសភា ឆ្នាំ២០០៩ | សង់អំពីឈើ ខ្ពស់ផុតពីទឹក |
| | ៣-១១-ការចុះល្បាត កន្លែងអភិរក្ស | -បទល្មើសនេសាទក្នុងកន្លែងអភិរក្សថយចុះ ៨០%<br>-ក្រុមល្បាតយ៉ាងហោច ៥នាក់ ក្នុងមួយក្រុម ចុះល្បាត៣ដង ក្នុងមួយខែ | ៦ ០៩១ ២០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| ៤-ការបណ្តុះ និងដាំព្រៃលិចទឹក | ៤-១-ការជ្រើសរើសអ្នកចូលរួម និងជ្រើសរើសគ្រាប់ | -យ៉ាងហោចប្រជាពលរដ្ឋ ២០ គ្រួសារ ចូលរួមកម្មវិធី បណ្តុះកូនឈើ<br>-គ្រាប់ឈើប្រភេទរាំង,ផ្តៅល ត្រូវបាន ប្រមូលទុក | ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកញ្ញា ឆ្នាំ២០០៨,២០០៩ | ខែតុលា ឆ្នាំ២០០៨,២០០៩ | |
| | ៤-២-ការរៀបចំថ្នាលបណ្តុះកូនឈើ | -ថ្នាលបណ្តុះកូនឈើ ទំហំ ៤ម គុណ ៣ម ចំនួន ២០ កន្លែង ត្រូវបានកសាងឡើង<br>-ដី ត្រូវបានប្រមូលច្រកថង់ ចំនួន ២៥០ថង់ នៅតាមថ្នាលនិមួយៗ | ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែមករា ឆ្នាំ២០០៩ ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៤-៣-ដំណើរការបណ្ដុះកូនឈើ | -គ្រាប់ឈើ ត្រូវបានដាក់ទៅក្នុងថង់ តាមថ្នាលគ្រួសារ<br>-កូនឈើ ចំនួន ៥ ០០០ដើម ត្រូវដុះចេញ និងលូតលាស់ ជាបន្តបន្ទាប់ | ១ ៦០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | |
| | ៤-៤-ការតាមដាន និងវាយតម្លៃ | -ការិតលូតលាស់កូនឈើ ត្រូវបានតាមដាន និងកត់ត្រា<br>-ចំណុចខ្សោយ ត្រូវបានកែលំអ | ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៩ ២០១០ | ខែកក្កដា ឆ្នាំ២០០៩ ២០១០ | |
| | ៤-៥-យុទ្ធនាការដាំកូនឈើ | -សមត្ថកិច្ចពាក់ព័ន្ធ និង សមាជិកសហគមន៍នេសាទយ៉ាងតិច ចំនួន ១០០នាក់ ចូលរួម ដាំកូនឈើព្រៃលិចទឹក<br>-កូនឈើចំនួន ១០ ០០០ដើម ត្រូវបានដាក់ដាំលើផ្ទៃដីទំហំ ៤ ហិកតា | ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | ខែមិថុនា ឆ្នាំ២០០៩ ២០១០ | |
| ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ៥-១-ចិញ្ចឹមត្រីអណ្តែង | -យ៉ាងតិចត្រីអណ្តែង ៤០គ្រើង នឹងត្រូវ ដាក់ចិញ្ចឹម ដែលមួយគ្រើង មាន កូនត្រី ១៤ ០០០ក្បាល<br>-វារីវប្បករ នឹងរកបានប្រាក់ចំណូលបន្ថែម សម្រាប់គ្រួសារ | ២ ៨០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដាឆ្នាំ២០០៨ | ខែមិថុនា ឆ្នាំ២០១០ | |
| | ៥-២-ចិញ្ចឹមត្រីប្រា | -យ៉ាងតិចត្រីប្រា ៤០គ្រើង នឹងត្រូវ ដាក់ចិញ្ចឹម ដែលមួយគ្រើង មាន កូនត្រី ១៤ ០០០ក្បាល | ១១ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដាឆ្នាំ២០០៨ | ខែមិថុនា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | -វារីវប្បករ នឹងរកបានប្រាក់ចំណូលបន្ថែម សម្រាប់គ្រួសារ | | | | | |
| | ៥-៣-ចិញ្ចឹមអន្ទង់ | -យ៉ាងតិច អន្ទង់៤៥ត្រើង នឹងត្រូវ ដាក់ចិញ្ចឹម ដែលមួយត្រើង មាន អន្ទង់ ១០០គ.ក្រ<br>-វារីវប្បករ នឹងរកបានប្រាក់ចំណូលបន្ថែម សម្រាប់គ្រួសារ | ៣៦ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| ៦-ផែនការអភិវឌ្ឍន៍មុខរបរ ក្នុងចំណោមសមាជិកសហគមន៍នេសាទ | ៦-១-ការចិញ្ចឹមជ្រូក | -យ៉ាងតិច មានគ្រួសារ ចំនួន ៣០ បានដាក់ជ្រូកចិញ្ចឹម ក្នុងរយៈពេលបីឆ្នាំ ដែលមានកូនជ្រូក០២ក្បាល ក្នុងមួយគ្រួសារ<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់គ្រួសារបន្ថែម | ១២ ០០០ ០០០រៀល (កូនជ្រូក១ក្បាលស្មើ ២០ម៉ឺនរៀល) | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែតុលា ឆ្នាំ២០១០ | |
| | ៦-២-ការចិញ្ចឹមមាន់ | -យ៉ាងតិច មានគ្រួសារ ចំនួន ៨០ បានដាក់មាន់ចិញ្ចឹម ក្នុងរយៈពេលបីឆ្នាំ ដែលមានមេមាន់ ០៥ក្បាល ក្នុងមួយគ្រួសារ<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់គ្រួសារបន្ថែម | ៨ ០០០ ០០០រៀល( មាន់០១ក្បាលស្មើ១ម៉ឺនរៀល) | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨ | ខែតុលា ឆ្នាំ២០១០ | |
| | ៦-៣-ការបណ្ដុះផ្សិតជាលក្ខណៈគ្រួសារ | -យ៉ាងតិច មានគ្រួសារ ១៥ បានទទួលវគ្គបណ្ដុះបណ្ដាល និងរៀបចំរងបណ្ដុះផ្សិត មួយគ្រួសារ ៥រង<br>-ទទួលបានប្រាក់ចំណូលទ្រទ្រង់គ្រួសារបន្ថែម | ១៥០០ ០០០រៀល( ១រងស្មើ ៥ដុល្លា) | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០០៨, ២០១០ | ខែឧសភា ឆ្នាំ២០០៨, ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧-ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍន៍សហគមន៍ | ៧-១-ភាគទានពីសមាជិកសហគមន៍ថ្មី | ធ្វើការឃោសនាជ្រើសរើសសមាជិកចូល ថ្មីរៀងរាល់ឆ្នាំ | ១៥០.០០០៛ | សហគមន៍នេសាទ | ២០០៨ | ២០១០ | |
| | ៧-២-ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍និងចូលរួមបង់ភាគទានប្រចាំឆ្នាំរៀលរាល់ឆ្នាំ | ១.៤១៦.០០០៛ | សហគមន៍នេសាទ | ២០០៨ | ២០១០ | |
| ៨-ផែនការពង្រឹងសមត្ថភាព សហគមន៍នេសាទ | ៨-១-ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | -វគ្គបណ្តុះបណ្តាលចំនួន ០៣ ដែលមានប្រជាពលរដ្ឋ ២០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេសចិញ្ចឹមត្រី<br>-ចលនាចិញ្ចឹមត្រីមានសន្ទុះកើនឡើង | ១ ៦២០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ | ខែកុម្ភៈ | រាល់ឆ្នាំ |
| | ៨-២-ការបណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត | -វគ្គបណ្តុះបណ្តាលចំនួន ០២ ដែលមានប្រជាពលរដ្ឋ ១០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេសបណ្តុះផ្សិត<br>-ចលនាបណ្តុះផ្សិតមានសន្ទុះកើនឡើង | ៧៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០០៨, ២០០៩ | ខែមីនា ឆ្នាំ២០០៨, ២០០៩ | |
| | ៨-៣-ការបណ្តុះបណ្តាលបច្ចេកទេសធ្វើជី អ៊ី អឹម | -វគ្គបណ្តុះបណ្តាលចំនួន ០២ ដែលមានប្រជាពលរដ្ឋ ១០នាក់ ក្នុងមួយវគ្គ ក្នុងមួយឆ្នាំ ទទួលបានការយល់ដឹងពីបច្ចេកទេសផលិតជី អ៊ី អឹម<br>-កាកសំណល់ត្រូវបានកែប្រែ | ៧៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨, ២០០៩ | ខែមេសា ឆ្នាំ២០០៨, ២០០០៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ជា ជី អ៊ី អឹម ដែលប្រើសម្រាប់ទប់ស្កាត់ជំងឺត្រី និងជម្រុញការលូតលាស់របស់ត្រី | | | | | |
| | ៨-៤-បណ្ដុះបណ្ដាល បច្ចេកទេសបណ្ដុះកូនឈើ | -ប្រជាពលរដ្ឋ ២០នាក់ បានយល់ដឹងពីសារៈប្រយោជន៍ព្រៃលិចទឹក និងបច្ចេកទេសដាំដុះ<br>-កូនឈើព្រៃលិចទឹកនឹងបានបណ្ដុះនៅតាមថ្នាល ប្រចាំគ្រួសារ | ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| | ៨-៥-បណ្ដុះបណ្ដាលកិច្ចការរដ្ឋបាល | -វគ្គបណ្ដុះបណ្ដាលចំនួន ០១ ដែលមានប្រជាពលរដ្ឋ ១៥នាក់ក្នុងមួយវគ្គ ទទួល បានការយល់ដឹងពីកិច្ចការរដ្ឋបាល<br>-ដំណើរការគ្រប់គ្រងរបស់សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | ៥៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |
| | ៨-៦-បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ | -គណៈកម្មការសហគមន៍ទាំង៩នាក់ រួម អ្នកពាក់ព័ន្ធ ៥នាក់ ទទួលការយល់ដឹងពីកាតព្វកិច្ច និងភារកិច្ច របស់អ្នកដឹកនាំ<br>-សហគមន៍មានដំណើរការល្អ | ៥៥០ ០០០រៀល | | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |
| | ៨-៧-បណ្ដុះបណ្ដាលជំនួញខ្នាតតូច | -មានគំនិតច្នៃប្រឌិតមុខរបរបន្ថែម ក្រៅពីនេសាទ<br>-យ៉ាងតិច ប្រជាពលរដ្ឋ | ៥៥០ ០០០រៀល | | ខែមេសា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ២០នាក់ រួមទាំងគណៈកម្មការ បានទទួលការយល់ដឹង | | | | | |
| | ៨-៨-បណ្តុះបណ្តាលការចិញ្ចឹមជន្លេន | -សមាជិកសហគមន៍ និង គណៈកម្មការ យ៉ាងតិច២០នាក់ ត្រូវបណ្តុះបណ្តាល និងក្លាយជាគ្រូបង្គោល<br>-មានប្រជាពលរដ្ឋ យ៉ាងតិច ៥០% នៃអ្នកបានរៀន អនុវត្តការចិញ្ចឹមជន្លេន | ៩៥០ ០០០រៀល | | ខែមករា ឆ្នាំ២០០៩ | ខែមករា ឆ្នាំ២០០៩ | |
| | ៨-៩-បណ្តុះបណ្តាលបច្ចេកទេស ធ្វើសារពើភ័ណ្ឌព្រៃលិចទឹក | -សមាជិកសហគមន៍ និង គណៈកម្មការ យ៉ាងតិច២០នាក់ ត្រូវបណ្តុះបណ្តាល និងក្លាយជាអ្នកអនុវត្តជាក់ស្តែង<br>-ព្រៃលិចទឹកត្រូវបានធ្វើសារពើភ័ណ្ឌ ចូលបញ្ជី | ៩៥០ ០០០រៀល | | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកុម្ភៈ ឆ្នាំ២០១០ | |
| | ៨-១០-ការផ្សព្វផ្សាយជាសាធារណៈ នូវចំណុចសំខាន់ៗ នៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | -ប្រជានេសាទយ៉ាងតិច៥០% បានដឹង និងឮ ជារៀងរាល់ឆ្នាំ ពីវិធានការគ្រប់គ្រងរបស់សហគមន៍<br>-ដំណើរការគ្រប់គ្រងរបស់សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | ៣០០ ០០០រៀល | សហគមន៍នេសាទ | ខែមករា, តុលា | ខែមករា, តុលា | រាល់ឆ្នាំ |
| | ៨-១១-សិក្ខាសាលាថ្នាក់ភូមិស្តីពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | -ថ្នាក់ដឹកនាំសហគមន៍ អង្គភាពពាក់ព័ន្ធ និងសមាជិកសហគមន៍នេសាទយ៉ាងតិច២០ | ៤០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៨ | ខែកក្កដា ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | នាក់ បានយល់ ពីវិធានការគ្រប់គ្រងរបស់ សហគមន៍<br>-ដំណើរការគ្រប់គ្រងរបស់សហគមន៍ ប្រព្រឹត្តិទៅដោយរលូន | | | | | |
| | ៨-១២-ទស្សនកិច្ចសិក្សា ក្នុងខេត្ត | -ចំណេះដឹង និងបទពិសោធន៍ត្រូវបានផ្លាស់ប្តូរ និងកែលំអចំនួន ២លើក ដែលមានអ្នកចូលរួម សរុបចំនួន ១៥នាក់<br>-មានសកម្មភាពថ្មី ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលនៃការធ្វើទស្សនកិច្ច | ២ ២២០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែវិច្ឆិកា ឆ្នាំ២០០៨, ២០០៩ | ខែវិច្ឆិកា ឆ្នាំ២០០៨, ២០០៩ | |
| | ៨-១៣-ទស្សនកិច្ចសិក្សា ក្រៅ ខេត្ត | -ចំណេះដឹង និងបទពិសោធន៍ត្រូវបានផ្លាស់ប្តូរ និងកែលំអចំនួន ១លើក ដែលមានអ្នកចូលរួម សរុបចំនួន ១០នាក់<br>-មានសកម្មភាពថ្មី ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលនៃការធ្វើទស្សនកិច្ច | ៣ ១០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | |
| | ៨-១៤-បណ្តុះបណ្តាលស្តីពីការសរសេរគម្រោងស្នើសុំ | -គណៈកម្មការសហគមន៍, សមាជិកសកម្ម មេភូមិ សរុបចំនួន ១៥នាក់ ទទួលបានការបណ្តុះបណ្តាល<br>-សហគមន៍ ធ្វើសំណើរសុំថវិកាពីម្ចាស់ជំនួយ ដើម្បីអនុវត្ត | ៦០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ ឆ្នាំ២០០៨ | ខែកុម្ភៈ ឆ្នាំ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ផែនការរបស់ខ្លួន | | | | | |
| ៩-ការចងក្រងក្រុមស្ត្រី | ៩-១-ការជ្រើសរើសស្ត្រីស្ម័គ្រចិត្តចងក្រងជាក្រុមទុនបង្វិល | -ស្ត្រី ចំនួន ១០នាក់ស្ម័គ្រចិត្តចូលរួមចងក្រងជាក្រុម<br>-ផ្តល់ឱកាសឱ្យស្ត្រី ចេះជួយគ្នាទៅវិញទៅមក<br>-ផ្តល់ឱកាសឱ្យស្ត្រី មានទុនប្រកបមុខរបរចិញ្ចឹមជីវិត | ៤០ ០០០រៀល | សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែមករា ឆ្នាំ២០០៨ | |
| | ៩-២-ការប្រជុំពិភាក្សារៀបចំច្បាប់របស់ក្រុម | -វិធានទាំងឡាយត្រូវបង្កើតឡើងដើម្បីសម្រួលដល់ដំណើរការប្រព្រឹត្តិទៅនៃ ក្រុម | ៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០០៨ | ខែមីនា ឆ្នាំ២០០៨ | |
| | ៩-៣-ការរៀបចំរចនាសម្ព័ន្ធរបស់ ក្រុម | -ក្រុមមានថ្នាក់ដឹកនាំ ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីសមាជិកក្រុម និងសហគមន៍ទាំងមូល | ៣០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមេសា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៨ | |
| ១០-ផែនការពង្រឹងការគ្រប់គ្រងរបស់សហគមន៍នេសាទ | ១០-១-ការកសាងទីស្នាក់ការសហគមន៍ | -ផែបណ្តែតទឹក ទំហំ៧ម គុណ ៦ម ធ្វើពីឈើ ប្រក់សង្ក័សីត្រូវបង្កើតឡើង<br>-ស្នាក់ការនឹងក្លាយជាទីតាំងសម្រួលឱ្យការគ្រប់គ្រង និងបណ្តុះបណ្តាល របស់សហគមន៍ | ១០ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកក្កដា ឆ្នាំ២០០៩ | ខែសីហា ឆ្នាំ២០០៩ | |
| | ១០-២-ទិញទូកអុំ ចំនួន ០១ គ្រឿង ទំហំ ៥មគុណ ១,២ម | -មានមធ្យោបាយសម្រាប់ចុះល្បាត កន្លែងនេសាទសហគមន៍ | ៨០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមីនា ឆ្នាំ២០០៨ | ខែមេសា ឆ្នាំ២០០៨ | |
| | ១០-៣-ទិញទូកចែវ ចំនួន០១ គ្រឿង ទំហំ៧មគុណ១,៥ម | -មានមធ្យោបាយសម្រាប់ចុះល្បាត កន្លែងនេសាទសហគមន៍ | ២ ៥០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកក្កដា ឆ្នាំ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | នេសាទ | | | |
| | ១០-៤-កាណូត ទំហំ៧ម គុណ១,៥ម ម៉ាស៊ីន ៣ឡុក | -មានមធ្យោបាយសម្រាប់ចុះល្បាត កន្លែងនេសាទសហគមន៍ | ២ ៩០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែកុម្ភៈ ឆ្នាំ២០១០ | ខែកក្កដា ឆ្នាំ២០១០ | |
| | ១០-៥-ទិញអាវភ្លៀង | -ក្រុមល្បាតមានអាវការពារភ្លៀង ទប់ស្កាត់ជំងឺដង្កាត់ផ្សេងៗ | ១៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| | ១០-៦-អង្រឹង | -ក្រុមល្បាតមានអង្រឹងដេក ហើយអាចការពារ សត្វខាំ ទប់ស្កាត់ជំងឺដង្កាត់ផ្សេងៗ | ៤៥០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែឧសភា ឆ្នាំ២០០៨ | ខែឧសភា ឆ្នាំ២០០៨ | |
| | ១០-៧-ប៉ាណូផ្សព្វផ្សាយ ដាក់ក្នុងភូមិ | -ប្រជាពលរដ្ឋកាន់តែយល់ច្បាស់ពីអត្ថប្រយោជន៍ធនធានធម្មជាតិ និងការហាមឃាត់ផ្សេងៗ<br>-ប៉ាណូធ្វើអំពីដែក មានគូររូបភាព ទំហំ ៣ម គុណ២,៥ម កំពស់២ម ត្រូវបានដាក់ចំទីប្រជុំជនភូមិ | ១ ២០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០១០ | ខែមេសា ឆ្នាំ២០១០ | |
| | ១០-៨-ការចុះល្បាត ក្នុងកន្លែង នេសាទសហគមន៍ | -បទល្មើសនេសាទ ត្រូវថយចុះយ៉ាងតិច៧០%<br>-ច្បាប់ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ ត្រូវបានអនុវត្ត | ៩ ០០០ ០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ខែមករា ឆ្នាំ២០០៨ | ខែធ្នូ ឆ្នាំ២០១០ | |
| | ១០-៩-ប្រជុំគណៈកម្មការតាម ដានអនុវត្ត ការផែនការ | -គណៈកម្មការតាមដាន និងជម្រុញ ត្រូវបង្កើតឡើង | ៣៤ ៥៦០០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍ | ខែមិថុនា ឆ្នាំ២០០៨, ០៩,១០ | ខែធ្នូ ឆ្នាំ២០០៨, ០៩,១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | -មានតម្លាភាព ក្នុងការអនុវត្ត | | នេសាទ | | | |
| | ១០-១០-ការប្រជុំប្រចាំខែ | -សមិទ្ធផល ត្រូវបង្ហាញ<br>-ចំណុចខ្សោយ ត្រូវលុបបំបាត់<br>-ផែនការអនុវត្តបន្ត ត្រូវរៀបចំឡើង | ២១០០០០០០រៀល | គំរោង, អង្គការ, ឃុំ, សហគមន៍នេសាទ | ២០០៨ | ២០១០ | រាល់ខែ |

# តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ២០០៨ | | | | | | | | | | | | ឆ្នាំ២០០៩ | | | | | | | | | | | | ឆ្នាំ២០១០ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.-ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១-១ | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | |
| ១-២ | | | | | | | | | | | | | ■ | | | | | | | | | | | | | | | | | | | | | | | |
| ១-៣ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ២- ការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-១ | | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | |
| ៣- ការកំណត់និងរៀបចំតំបន់អភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-១ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-២ | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៣ | | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៤ | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| ៣-៥ | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៦ | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | |
| ៣-៧ | | | | | | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | | |
| ៣-៨ | | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | |
| ៣-៩ | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣-១០ | | | | | | | | | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | |
| ៣-១១ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៤-ការបណ្ដុះ និងដាំព្រៃ លិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤-១ | | | | | | | | | ■ | ■ | | | | | | | | | | | ■ | ■ | | | | | | | | | | | | | | |
| ៤-២ | | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | | |
| ៤-៣ | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៤-៤ | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៤-៥ | | | | | | | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | |
| ៥-ផែនការអភិវឌ្ឍន៍ វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥-១ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥-២ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥-៣ | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៦-ផែនការអភិវឌ្ឍន៍ មុខរបរ ក្នុង ចំណោម សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦-១ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | |
| ៦-២ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | |
| ៦-៣ | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | |
| ៧-ផែនការថវិកាទ្រទ្រង់ សំរាប់ អភិវឌ្ឍន៍ សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧-១ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧-២ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨-ផែនការពង្រឹងសមត្ថភាព សហគមន៍ នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨-១ | | ■ | | | | | | | | | | | | ■ | | | | | | | | | | | | ■ | | | | | | | | | | |

| |
|---|
| ៨-២ |
| ៨-៣ |
| ៨-៤ |
| ៨-៥ |
| ៨-៦ |
| ៨-៧ |
| ៨-៨ |
| ៨-៩ |
| ៨-១០ |
| ៨-១១ |
| ៨-១២ |
| ៨-១៣ |
| ៨-១៤ |
| ៩-ការចងក្រងក្រុមស្ត្រី |
| ៩-១ |
| ៩-២ |
| ៩-៣ |
| ១០-ផែនការពង្រឹងការគ្រប់គ្រង របស់ សហគមន៍នេសាទ |
| ១០-១ |
| ១០-២ |
| ១០-៣ |
| ១០-៤ |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១០-៥ | | | | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០-៦ | | | | | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០-៧ | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | | | | | | | | |
| ១០-៨ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០-៩ | | | | | | ■ | | | | | | ■ | | | | | | ■ | | | | | | ■ | | | | | | ■ | | | | | | ■ |
| ១០-១០ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

ថ្ងៃទី ២០ ខែ ៨ ឆ្នាំ២០០៨

ប្រធានគណៈកម្មការសហគមន៍នេសាទ

ម៉ៅ_ពេញ

តាមរយៈ មេឃុំកោះជីវាំង

ហត្ថលេខា

ម៉ុន_បេង

លេខៈ ...................... ជផ

បានឃើញ និងឯកភាព

ថ្ងៃទី ......... ខែ ........... ឆ្នាំ ...............

ប្រធានរដ្ឋបាលជលផល